# ព្រឹត្តិបត្រព័ត៌មាន

គម្រោងអភិវឌ្ឍន៍សុខភាពសិក្សាសម្រាប់កុមារកម្ពុជា

លេខ ២០ | ថ្ងៃអង្គារ ១កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹង ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២៤

## វគ្គបណ្ដុះបណ្ដាលគ្រូឧទ្ទេសសុខភាពសិក្សាលើកទី ១៨



## ការសិក្សាស្រាវជ្រាវមេរៀន

វគ្គបណ្ដុះបណ្ដាលគ្រូឧទ្ទេសសុខភាពសិក្សាលើកទី ១៨ បានប្រព្រឹត្តទៅចាប់ពីថ្ងៃទី ០៨-១១ ខែកក្កដា នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ (PTEC) និងវិទ្យាស្ថានគរុកោសល្យបាត់ដំបង (BTEC)។ វគ្គបណ្ដុះបណ្ដាលលើកនេះផ្ដោតទៅលើ «ការសិក្សាស្រាវជ្រាវមេរៀន» សម្រាប់ថ្នាក់សុខភាពសិក្សា។ ការរៀនអំពីការសិក្សាស្រាវជ្រាវមេរៀននេះ បើទោះបីជាសម្រាប់សុខភាពសិក្សាក្ដី ក៏អាចមានប្រយោជន៍សម្រាប់ការបង្រៀនមុខវិជ្ជាដទៃផ្សេងទៀតដែលបង្រៀនដោយគ្រូឧទ្ទេសសុខភាពសិក្សានៅ TECs ផងដែរ។ ផ្ទុយមកវិញ គ្រូឧទ្ទេសក៏អាចប្រើការសិក្សាស្រាវជ្រាវមេរៀននៃមុខវិជ្ជាផ្សេងទៀតសម្រាប់ថ្នាក់សុខភាពសិក្សាផងដែរ។ គរុនិស្សិតដែលបានចូលរួមរៀននៅក្នុងថ្នាក់បង្រៀនរបស់គ្រូឧទ្ទេសយើងលើកនេះគឺជាគរុនិស្សិតឆ្នាំទី ៣។ ពួកគាត់មិនទាន់ធ្លាប់បានចូលរៀនថ្នាក់សុខភាពនៅឡើយទេ ដូច្នេះវាពិតជាគួរអោយចាប់អារម្មណ៍យ៉ាងខ្លាំង នៅពេលដែលបានឃើញការខិតខំប្រឹងប្រែងរៀនដោយប្រើប្រាស់សៀវភៅសិក្សាគោល និងបានឃើញការចូលចិត្តរបស់ពួកគាត់ចំពោះថ្នាក់សុខភាពនេះ។

ជាមួយគ្នានេះដែរ យើងក៏មានទុកពេលវេលាសម្រាប់ឱ្យសមាជិកនៅក្នុងវគ្គទាំងអស់បានចែករំលែកការយល់ឃើញរបស់ពួកគាត់មិនត្រឹមតែអំពីការសិក្សាស្រាវជ្រាវមេរៀនសម្រាប់ថ្នាក់សុខភាពសិក្សាប៉ុណ្ណោះទេ ប៉ុន្តែក៏ចែករំលែកអំពីការយល់ឃើញទៅលើគម្រោង SHCC ផ្ទាល់ផងដែរ។ មួយឆ្នាំម្ដង សមាជិកម្នាក់ៗនៃក្រុម SHCC មានឱកាសបញ្ចេញនូវមតិនិងអារម្មណ៍ពិតរបស់ខ្លួនចំពោះគម្រោងនេះដើម្បីកែលម្អឱ្យកាន់តែប្រសើរឡើង។ ក្រុមការងារ SHCC សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហប្រតិបត្តិការ និងការយកចិត្តទុកដាក់ចំពោះគម្រោងនេះ។







## ការសិក្សាស្រាវជ្រាវមេរៀននៅ PTEC

គ្រូឧទ្ទេសសុខភាពសិក្សា អ្នកគ្រូ សាន ស្រីរី អញ្ជើញមកពីវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ (PTEC) បានធ្វើបទបង្ហាញដល់គរុនិស្សិតអំពី ជំពូកទី ៧៖ ជំងឺឆ្លង និងការបង្ការជំងឺ។ ប្រធានបទសំខាន់ៗដែលបានលើកមករួមមាន «និយមន័យនៃជំងឺឆ្លង» «កត្តាចម្បងទាំងបីនៃការបង្ករោគ» និង «វិធីបង្ការការពុលចំណីអាហារ»។ ការណែនាំអំពីវិធីថែទាំអ្នកពុលចំណីអាហារគឺមានលក្ខណៈជាក់លាក់ណាស់ ដែលនេះគឺឆ្លុះបញ្ចាំងអំពីសាវតាផ្នែកវេជ្ជសាស្ត្ររបស់អ្នកគ្រូ ស្រីរី។ អ្នកគ្រូបានក្លាយជាគ្រូឧទ្ទេសសុខភាពសិក្សានៅ PTEC បន្ទាប់ពីឆ្លងកាត់បទពិសោធន៍ជាវេជ្ជបណ្ឌិតហើយ។





## ការសិក្សាស្រាវជ្រាវមេរៀននៅ BTEC

គ្រូឧទ្ទេសសុខភាពសិក្សា អ្នកគ្រូ សារ សុមនា អញ្ជើញមកពីវិទ្យាស្ថានគរុកោសល្យបាត់ដំបង (BTEC) ជាអ្នកធ្វើបទបង្ហាញ ជំពូកទី ៨៖ សុខភាពមាត់ធ្មេញ។ ថ្នាក់រៀនបានចាប់ផ្ដើមដោយការបង្ហាញអំពីសម្អេកធ្មេញ (លាបពណ៌ធ្មេញ) ដោយគរុនិស្សិតពីរនាក់។ នៅពេលរៀនពីរបៀបដុសធ្មេញឱ្យបានត្រឹមត្រូវ គរុនិស្សិតត្រូវបានចែកជាក្រុម បន្ទាប់មកចែកតួនាទីសមាជិកក្រុមមាន អ្នកដុសធ្មេញ អ្នកមើលសៀវភៅសិក្សាគោលនិងពន្យល់ ព្រមទាំងអ្នកមើល ដែលញ៉ាំងឱ្យមានសកម្មភាពរស់រវើក។ អ្នកគ្រូ សុមនា បានផ្ដល់ក្រដាសណែនាំដោយចង់រំលឹកថា វាអាចគ្មានអគ្គិសនីប្រើប្រាស់សម្រាប់សម្ភារៈបង្រៀនទំនើបទេ នៅតាមសាលារៀនតំបន់ដាច់ស្រយាលដែលគរុនិស្សិតនឹងត្រូវចាត់តាំងទៅធ្វើជាគ្រូបង្រៀននាពេលខាងមុខ។





## សារៈសំខាន់នៃការប្រជុំឆ្លុះបញ្ចាំង

មុនពេលកិច្ចប្រជុំត្រួតពិនិត្យ លោកសាស្ត្រាចារ្យបណ្ឌិត អាសាគីវ៉ា បានណែនាំដល់គ្រូឧទ្ទេសអំពីចំណុចសំខាន់នៅក្នុងកិច្ចប្រជុំឆ្លុះបញ្ចាំងបន្ទាប់ពីការបង្រៀន។

«អ្វីដែលសំខាន់គឺគោរពចេតនារបស់គ្រូឧទ្ទេសប្រចាំថ្នាក់។ សូមគោរពការឆ្លុះបញ្ចាំងរបស់គ្រូឧទ្ទេសប្រចាំថ្នាក់ទៅលើការអនុវត្តនៃការបង្រៀន។ សូមព្យាយាមចូលរួមក្នុងការផ្លាស់ប្ដូរយោបល់ ជាជាងការរិះគន់ទៅលើភាគីម្ខាងៗ។ ការសិក្សាស្រាវជ្រាវមេរៀនមិនមែនជាការវាយតម្លៃសម្រាប់គ្រូប្រចាំថ្នាក់នោះទេ ប៉ុន្តែជាការផ្ដល់ត្រឡប់មកកាន់ខ្លួនយើងផ្ទាល់។ ដូច្នេះ ខ្ញុំសូមឱ្យអ្នកទាំងអស់គ្នាគិតថា វាមិនមែនដើម្បីជាប្រយោជន៍ដល់គ្រូឧទ្ទេសប្រចាំថ្នាក់នោះទេ ប៉ុន្តែសម្រាប់ការយល់ដឹងរបស់ខ្លួនអ្នកផ្ទាល់។»




# ទស្សនកិច្ចសិក្សាទៅកាន់ ហ្វារពន្លឺសិល្បៈ ខេត្តបាត់ដំបង

នៅថ្ងៃទី ១១ ខែកក្កដា ក្រុមការងាររបស់ SHCC បានចុះទៅទស្សនកិច្ចសិក្សានៅសាលាហ្វារពន្លឺសិល្បៈ ដែលជាផ្នែកនៃកម្មវិធីរបស់វគ្គបណ្តុះបណ្តាលគ្រូឧទ្ទេសសុខភាពសិក្សាលើកទី ១៨។ ហ្វាពន្លឺសិល្បៈគឺជាសាលាសិល្បៈនិងសៀកមិនរកប្រាក់ចំណេញដែលមានទីតាំងនៅក្នុងខេត្តបាត់ដំបង និងដែលផ្តល់សិទ្ធិអំណាចដល់កុមារ យុវជន និងសហគមន៍ តាមរយៈកម្មវិធីជំនួយផ្នែកសិល្បៈ ការអប់រំ និងសង្គម។

## ដំណើរទស្សនាបរិវេណសាលា



ក្នុងអំឡុងពេលដំណើរទស្សនាបរិវេណសាលា បុគ្គលិក របស់ហ្វារបានបង្ហាញយើងពីទីតាំងនានា ហើយយើងក៏បានឃើញសកម្មភាពសិល្បៈផ្សេងៗផងដែរ។ ពួកគេផ្តល់ជូននូវកម្មវិធីអប់រំផ្លូវការនៅក្នុងសាលាមត្តេយ្យ និងសាលារដ្ឋរបស់ហ្វារ ក៏ដូចជាសកម្មភាពអប់រំក្រៅផ្លូវការ និងការច្នៃប្រឌិតនៅក្នុងមជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារ និងបណ្ណាល័យរបស់ពួកគេផងដែរ ដើម្បីជួយកុមារក្នុងសហគមន៍ឱ្យពង្រីកទាំងជំនាញរឹង និងជំនាញទន់របស់ពួកគេ។

## សិក្ខាសាលាអំពីអាហារូបត្ថម្ភ និងសុខភាព

បន្ទាប់ពីដំណើរទស្សនាបរិវេណសាលា ក្រុមការងារ SHCC ក៏បានរៀបចំជាសិក្ខាសាលាស្តីពីអាហារូបត្ថម្ភ និងសុខភាព ដែលបង្រៀនដោយ PTEC និង BTEC សម្រាប់កុមារនៅហ្វារពន្លឺសិល្បៈ។ កុមារជាង 30នាក់ បានចូលរួមក្នុងសិក្ខាសាលានេះ ហើយមើលទៅពួកគេរីករាយជាមួយនឹងការសិក្សានេះណាស់។

ខ្លឹមសារនៃមេរៀនដែលបានផ្តល់ជូននឹងត្រូវប្រគល់ជូនលោកគ្រូអ្នកគ្រូនៅសមាគមហ្វារពន្លឺសិល្បៈដើម្បីបង្រៀន និងប្រើប្រាស់នៅក្នុងថ្នាក់រៀននាពេលអនាគតក្នុងការលើកកម្ពស់សុខភាពកុមារ។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះហ្វារពន្លឺសិល្បៈ សម្រាប់ឱកាសដ៏ល្អនេះ។









Photos: © Phare Ponleu Selpak

## ហ្គេមកាត ស្តីពីសមត្ថភាពសង្គម និង សមត្ថភាពអារម្មណ៍

នៅក្នុងការបណ្តុះបណ្តាលលើកទី ១៨ យើងបានលេងហ្គេមកាត ស្តីពីសមត្ថភាពសង្គម និង សមត្ថភាពអារម្មណ៍ ដែលផលិតដោយលោកសាស្ត្រាចារ្យបណ្ឌិត អាសាគីវ៉ា។ នេះជាលើកទីពីរហើយសម្រាប់ការលេងហ្គេមកាតនេះ។ គ្រូឧទ្ទេសបានបង្ហាញការវិវឌ្ឍក្នុងការយល់ដឹងពីរបៀបលេងហ្គេមជាងមុន និងមានភាពសកម្មជាខ្លាំង។ វាជាឱកាសដ៏ល្អមួយដើម្បីឆ្លុះបញ្ចាំងពីខ្លួនឯង និងស្វែងយល់ពីអ្នកដទៃ។ គ្រូឧទ្ទេសក៏បានបង្ហាញពីបំណងចង់បង្កើតហ្គេមកាតបែបនេះសម្រាប់មុខវិជ្ជាផ្សេងៗទៀតផងដែរ!



NEWSLETTER
School Health Development Project for all Cambodian Children
Supported by THE NIPPON FOUNDATION
VOLUME 20 | 3 September, 2024

# The 18th School Health Lecturer Training



## Lesson Study

The 18th School Health Lecturer Training was held from 8th to 11th July at Phnom Penh Teacher Education College (PTEC) and Battambang Teacher Education College (BTEC). This training mainly consisted of Lesson Study on School Health class. Learning about Lesson Study in School Health can be useful for other subjects that lecturers teach at TECs. Conversely they could also refer to the Lesson Study in other subjects. The student teachers who took the class were Year 3. They had not yet taken a health class, so it was impressive to see how hard they worked through the textbook and how much they enjoyed the class.
Also, we had a time which all members shared their thoughts about not only Lesson Study on School Health but also SHCC project itself. Once a year, each member of SHCC team has an opportunity to give his or her honest opinion on the project to improve it. The SHCC team would like to thank you so much for their cooperation and dedication to the project.







## Lesson Study at PTEC

School Health lecturer Ms. San Sreyry from Phnom Penh Teacher Education College (PTEC) had a demonstration lesson to student teachers about Chapter 7: Infection Disease and its prevention. The main topics were "Definition of Infectious diseases," "Three major factors of infection," and "How to prevent food poisoning.“ The advice on how to take care of a person who gets food poisoning was very specific, reflecting Ms. Sreyry's medical background. She became a School Health lecturer at PTEC after her experience as a medical doctor.







## Lesson Study at BTEC

School Health lecturer Ms. Sar Somnea from Battambang Teacher Education College (BTEC) gave a demonstration lesson. The lesson featured Chapter 8: Dental health. The class started with a plaque disclosing (tooth coloring) by two student teachers. When learning how to brush their teeth properly, student teachers were divided into groups, and their roles were divided into those who brushed their teeth, those who looked at the textbook and explained, and those who watched, which led to some lively activities. Ms. Somnea provided paper-based instruction, keeping in mind that there would be no electricity if the student teachers were assigned as teachers to a school in a remote area in the future.







## Importance of the Reflection meeting

Before the review meeting, Professor Dr. Asakura advised lecturers on what is important in the reflection meeting after the lesson.

“What is important is to respect the intentions of the class lecturer. Please respect the class lecturer‘s reflections on the practice. Please try to engage in dialogue rather than one-sided criticism. The lesson study is not an evaluation for the class lecturer, but how to give back to ourselves. Therefore, I would like you to think that it is not for the benefit of the class lecturer , but rather for your own awareness. ”





# Visiting Phare Ponleu Selpak in Battambang

On 11th July, SHCC team visited Phare Ponleu Selapak as a field study of the 18th School Health Lecturer Training. Phare Ponleu Selpak is a non-profit arts and circus school located in Battambang, that empowers children, youth, and communities through artistic, educational, and social support programs.

## Campus Tour

During the campus tour, Phare staff showed us around and we saw various art activities. They offer formal educational programs in their Kindergarten and Phare public school, as well as informal educative and creative activities in their Child Development Center and library to help community children to expand both their hard and soft skills.



## Nutrition and health Workshop

After the campus tour, SHCC team held a workshop on nutrition and health. PTEC and BTEC lectures gave a lesson to children in Phare Ponleu Selpak. More than 30 children join the workshop and looked joy with the study.

The content of the lessons provided will be handed over to the teachers at Phare Ponleu Selpak to teach and will be used for future classes to promote the children's health. We would like to thank Phare Ponleu Selpak for this wonderful opportunity.









Photos: © Phare Ponleu Selpak

## Social and Emotional Competencies game

In the 18th Training, we played the social and social and emotional competencies card game that is produced by Dr. Asakura. This is the second time for the game. Lecturers made progress in understanding how to play the game, and it was very active. It seemed to be a good opportunity to reflect on oneself and to learn about others. Lecturers also expressed a desire to create such a card game for other subjects!

